00686139

E9/30/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ** / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការអន្តោគរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនាការបឋម**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 03 / 05 / 2011
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមដាក់ការអង្កេតរបស់គាត់ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ដែលខ្លួន [sic] មានបំណងលើកនៅសវនាការបឋម[1] ។ ការអង្កេតទាំងនេះត្រូវធ្វើឡើងជាចាំបាច់ ពីព្រោះសហព្រះរាជអាជ្ញាបានជូនដំណឹងអង្គជំនុំជម្រះសាលាដំបូងថាខ្លួននឹង “*ស្នើសុំធ្វើការកំណត់បទចោទជាថ្មីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីបញ្ចូល៖* (ក) ជម្លោះប្រដាប់អាវុធមិនតម្រូវជាភស្តុតាងសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ, (ខ) ការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, (គ) ការប្រព្រឹត្តឧក្រិដ្ឋកម្មនានាតាមទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម (“JCE III”) (*វិធាន ៩៨*)”[2] ។ ដោយសារបញ្ហាទាំងនេះពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង កសព គួរតែបានលើកបញ្ហាទាំងនេះឱ្យបានត្រឹមត្រូវ មិនឱ្យហួសពីរយៈពេល ៣០ ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ[3] ។ សហព្រះរាជអាជ្ញាមិនបានធ្វើយ៉ាងដូច្នេះទេ ហើយពេលនេះជាពេលវេលាដែលរារាំងសហព្រះរាជអាជ្ញាមិនឱ្យលើកបញ្ហាយុត្តាធិការទាំងនេះ ។ បើទោះបីជាបញ្ហាទាំងនេះនៅតែអាចលើកឡើង ក៏វិធាន ៨៩ មិនអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់បទចោទជាថ្មីដែរ ។ បើសិនអង្គជំនុំជម្រះសាលាដំបូងសម្រេចថា កសព អាចលើកបញ្ហាទាំងនេះនៅសវនាការបឋម នោះមេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យ កសព ផ្តល់សារណាជាលាយលក្ខណ៍លំអិតនៅមុនសវនាការបឋម ដោយបញ្ជាក់ពីអំណះអំណាងរបស់ខ្លួនថា ហេតុអ្វីបានជាការកំណត់បទចោទជាថ្មី ត្រូវបានអនុញ្ញាត និងអនុញ្ញាតឱ្យមេធាវីការពារក្តីដាក់សារណាឆ្លើយតបជាលាយលក្ខណ៍អក្សរ ។

## I ច្បាប់ដែលយកមកអនុវត្ត

១. វិធាន ៨៩ នៃវិធានផ្ទៃក្នុងរបស់ អវតក ចែងថា៖

**វិធាន ៨៩: អញ្ញត្រកម្ម**

(វិសោធនកម្ម ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០៨ និង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ និងថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១១)

---

[1] ការបង្ហាញរបស់សហព្រះរាជអាជ្ញាពីបញ្ហាច្បាប់ដែលសហព្រះរាជអាជ្ញាមានបំណងលើកឡើងនៅសវនាការបឋម ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ E9/30 (“ការជូនដំណឹងរបស់ កសព អំពីបញ្ហាច្បាប់”) ។

[2] ដូចខាងលើ នៅកថាខណ្ឌទី ៩ ។

[3] សូមមើលវិធាន ៨៩ ។

១. អញ្ញត្រកម្មទាក់ទងទៅនឹង:

ក- យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

ខ- ការរលត់បណ្តឹងអាជ្ញា

គ- មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ

ត្រូវលើកឡើងយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ ។

២. អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់ឱ្យភាគីម្ខាងទៀតនូវឱកាសឆ្លើយតបទៅនឹងអញ្ញត្រកម្ម។

៣. អង្គជំនុំជម្រះសាលាដំបូង ត្រូវសម្រេចជាបន្ទាន់អំពីអញ្ញត្រកម្មតាមសេចក្តីសម្រេចមួយដែលមានសំអាងហេតុ ឬ នៅពេលជំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី។ ដំណើរការនីតិវិធីត្រូវបន្តលើកលែងតែអង្គជំនុំជម្រះចេញសេចក្តីសម្រេចភ្លាម ដែលមានអានុភាពបញ្ចប់កិច្ចដំណើការនីតិវិធី។

២. វិធាន ៩៨(២) ចែងថា៖

សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំ-ជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ ។ អង្គជំនុំជម្រះត្រូវធ្វើការវិនិច្ឆ័យតែចំពោះជនជាប់ចោទប៉ុណ្ណោះ។ ប្រសិនបើបុគ្គលណាមួយ ដែលមកបង្ហាញខ្លួនក្នុងពេលជំនុំជម្រះក្នុងឋានៈជាសាក្សី ត្រូវបានសង្ស័យថាបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬបានសមគំនិតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ អង្គជំនុំជម្រះនឹងធ្វើការជំនុំជម្រះលើបុគ្គលនោះបានលុះត្រាតែនៅក្រោយពេលដែលជននោះត្រូវបានចោទប្រកាន់ និងមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដូចចែងនៅក្នុងវិធានផ្ទៃក្នុងនេះប៉ុណ្ណោះ។

## II. ការអង្កេត

៣. ការជូនដំណឹងរបស់ កសព ទៅអង្គជំនុំជម្រះសាលាដំបូងថាខ្លួន "នឹងស្នើសុំឱ្យធ្វើការកំណត់បទ

00686142



ចោទជាថ្មីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបញ្ចូលៈ (ក) ជម្លោះប្រដាប់អាវុធមិនតម្រូវឱ្យមានការបង្ហាញឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, (ខ) ការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, (គ) ការប្រព្រឹត្តឧក្រិដ្ឋកម្មនានាតាមទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ("JCE III") (*វិធាន ៨៩*)"[4] គឺជាការលើកឡើងនូវបញ្ហាយុត្តាធិការ[5] ។

៤. អនុលោមតាមវិធាន ៨៩ បញ្ញា "ទាក់ទងនឹងអញ្ញត្រកម្មរបស់អង្គជំនុំជម្រះ" ត្រូវលើកឡើងយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ[6] ។

៥. ដីកាដំណោះស្រាយចូលជាស្ថាពរនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១[7] ធ្វើឱ្យកាលបរិច្ឆេទដើម្បីលើក

---

[4] ការជូនដំណឹងរបស់ កសត អំពីបញ្ហាច្បាប់ នៅកថាខណ្ឌទី៩ ។

[5] អង្គបុរេជំនុំជម្រះកត់សម្គាល់ថានៅក្នុងអនុមូលដ្ឋានមួយចំនួននៃមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ...រួមបញ្ចូលទាំងអនុមូលដ្ឋានទី៣ (ទឡ្ហីករណ៍ស្តីពីចំណងពាក់ព័ន្ធ)។ .... អនុមូលដ្ឋានទី១៤ ("ទឡ្ហីករណ៍ស្តីពីការរំលោភសេពសន្ថវៈ")។ ...សហព្រះរាជអាជ្ញាលើកអំណះអំណាងពីអត្ថិភាពផ្លូវច្បាប់ចន្លោះឆ្នាំ១៩៧៥-៧៩ នៃប្រភេទមួយចំនួននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលតំណាងឱ្យទឡ្ហីករណ៍ដែលជាខ្លឹមសារនៃការវាយតម្លៃស្របតាមគោលការណ៍នីត្យានុកូលភាព ហើយដូច្នេះ តំណាងឱ្យការប្តឹងជំទាស់យុត្តាធិការដែលអាចទទួលយកបាន" ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ D427/I/30 ។ មានការប្តឹងជំទាស់ជាច្រើនទៅនឹងយុត្តាធិការរបស់ ICTY ដោយជនជាប់ចោទដែលត្រូវចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងទម្រង់នៃការទទួលខុសត្រូវ ដូចជា ICE និងការទទួលខុសត្រូវជាថ្នាក់លើ ។ បណ្តឹងឧទ្ធរណ៍បែបនេះតែងតែផ្អែកលើទឡ្ហីករណ៍ដែលថាទម្រង់នៃការទទួលខុសត្រូវទាំងនេះមិនមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធ ឬមិនអាចអនុវត្តបាននៅពេលវេលាជាក់លាក់ ហើយការអនុវត្តរបស់វាអាចរំលោភគោលការណ៍នីត្យានុកូលភាព ។ យុត្តិសាស្ត្ររបស់ ICTY បានទទួលយកការប្តឹងជំទាស់យុត្តាធិការទាំងនេះ ។ ទាក់ទងនឹងថាតើភាពអាចទទួលយកបាននៅ អវតក នៃសហឧក្រិដ្ឋកម្មរួមបង្កើតបានជាការប្តឹងជំទាស់យុត្តាធិការដែរ ឬយ៉ាងណា អង្គបុរេជំនុំជម្រះរកឃើញថា អវតក គឺជាស្ថាប័នមួយប្រៀបដូចតុលាការបណ្តោះអាសន្ន" ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ D97/14/15 នៅកថាខណ្ឌទី២៣-២៤ ។

[6] បញ្ជាក់បន្ថែម ។

[7] "អនុលោមតាមដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (E9) ពេលវេលាកំណត់ដែលមានចែងនៅក្នុងវិធាន ៨០(១) និង(២) នៃវិធានផ្ទៃក្នុង និងវិធាន ៨៩ ចាប់ផ្តើមគិតពីថ្ងៃសុក្រ ទី១៤ ខែ មករា ឆ្នាំ២០១១"។ អនុស្សរណៈពីអ្នកនាង Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅភាគីទាំងអស់នៅក្នុងករណី ០០២ ការជូនដំណឹងជាមុននៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើញត្តិ E14, E15, E9/2, E9/3, E/24 and E27, ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១១ E35 ទំព័រ ២។

បញ្ហាទាំងនេះ គឺនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១។ កសព មិនបានលើកបញ្ហាទាំងនេះនៅកាលបរិច្ឆេទនេះទេ ហេតុដូច្នេះ កសព ត្រូវបានរារាំងមិនឲ្យលើកបញ្ហានេះនៅពេលនេះ ។ កសព ខកខានមិនបានបំពេញភារកិច្ចប្រកបដោយវិរិយភាព នៅក្នុងការលើកបញ្ហាទាំងនេះ ភ្លាមៗបន្ទាប់ពីអង្គជំនុំជម្រះបានទទួលសំណុំរឿង និងនៅមុនកាលបរិច្ឆេទដែលកំណត់ដោយវិធានផ្ទៃក្នុង[8] ។

៦. កសព ប៉ុនប៉ងលើកបញ្ហានានាដែលច្បាស់ណាស់ថាបញ្ហាទាំងនេះបង្កើតបានជាអញ្ញត្រកម្មតាមវិធាន ៨៩ ។ ការដកចេញនៃចំណងពាក់ព័ន្ធនូវលក្ខខណ្ឌតម្រូវជម្លោះប្រដាប់អាវុធសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបន្ថែមការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបន្ថែម JCE III ដែលចំណុចនីមួយៗបង្កើតបានជាការប្តឹងជំទាស់យុត្តាធិការរបស់ អវតក ដោយសារយុត្តាធិការនេះមិនត្រូវបានដាក់កម្រិតនៅក្នុងដីកាដំណោះស្រាយ ។

៧. ដីកាដំណោះស្រាយត្រូវបានកែតម្រូវដោយអង្គបុរេជំនុំជម្រះ នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (ដែលលើកឡើងពីបញ្ហាយុត្តាធិការ ស្របតាមវិធាន ៧៤(៣)(ក) ដោយៈ ក. បន្ថែម "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធ" ចំពោះ "លក្ខខណ្ឌតម្រូវនៅក្នុងជំពូក IV(ក) នៃផ្នែកបី, ខ. លុបចេញការរំលោភសេពសន្ថវៈពីកថាខណ្ឌទី ១៦១៣ និង គ. រក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតនៅកថាខណ្ឌទី ១៤៣៣ ថាអង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងជាតិ នៅក្នុងទម្រង់នៃការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត[9] ។ ដីកាដំណោះស្រាយលុបរាល់ការយោងទាំងអស់ចំពោះ JCE III ដោយសារអង្គបុរេជំនុំជម្រះបានយល់ឃើញលើកមុនថា JCE III មិនមានអត្ថិភាពនៅក្នុងច្បាប់ទំនៀម

---

[8] សូមមើលសេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដិតចិត្តចៅក្រម និល ណុន និងបញ្ហាដែលពាក់ព័ន្ធ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១១ E5/3 នៅកថាខណ្ឌទី២ ដែលនៅក្នុងសេចក្តីសម្រេចនេះអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់កាតព្វកិច្ចនៃការយកចិត្តទុកដាក់ម៉ត់ហ្មត់របស់ភាគី។ សូមមើលផងដែរករណីរដ្ឋអាជ្ញា តទល់ *Delalić និងអ្នកដទៃទៀត* IT-96-21-A, សាលដីកា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ នៅកថាខណ្ឌ ៦៣១ ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូល ICTY យល់យ៉ាងថា "ការខកខានរបស់មេធាវីក្នុងការជំទាស់តែងតែបង្ហាញថាមេធាវីយល់ឃើញនៅពេលនោះថា បញ្ហានានាដែលចៅក្រមមិនបានយកចិត្តទុកដាក់ មិនមានសារៈសំខាន់ដល់ករណីរបស់គាត់ ហើយថានីតិវិធីមិនអាចបន្តបានទេ បើគ្មានការយកចិត្តទុកដាក់នោះ។ គោលការណ៍នេះអនុវត្តដល់ព្រះរាជអាជ្ញា ក៏ដូចជាមេធាវីការពារក្តីដែរ ។

[9] សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១១ D427/1/26 នៅកថាខណ្ឌទី ៧ ។

00686144



ទម្លាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥-៧៩ ទេ ហើយវាមិនអាចអនុវត្តនៅ អវតក បានឡើយ[10] ។

៨. សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងករណី ០០១ បានផ្តល់ដំបូន្មាននៅសវនាការបឋមថា "បើទោះបីជានៅសវនាការនេះយើងគ្មានបំណងលើកមកពិភាក្សា ឬលើកឡើងនូវបញ្ហាច្បាប់ណាមួយក៏យើងចង់យកឱកាសនេះជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីទាំងអស់ថានៅសវនាការក្នុងអំឡុងពេលដំណើរការនីតិវិធី សហព្រះរាជអាជ្ញាមានបំណងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណា ភាពអនុវត្តបាននៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅក្នុងដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ"[11] ។ ការលើកឡើងបញ្ហានេះនៅសវនាការបឋម គឺជានីតិវិធីត្រឹមត្រូវនៅក្នុងករណីនោះ[12] ពីព្រោះវិធាន ៨៩(១) ចែងនៅពេលនោះថា "អញ្ញត្រកម្មទាក់ទងនឹងៈ ក) យុត្តាធិការរបស់អង្គជំនុំជម្រះ... **<u>ត្រូវលើកនៅសវនាការបឋម</u>** បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ[13] ។ ទើបតែការធ្វើវិសោធនកម្មលើកទីបួននៃវិធានផ្ទៃក្នុងនាខែកញ្ញា ឆ្នាំ២០០៩

---

[10] សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ D97/14/15 ។

[11] *ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច* ០០១/១៨-០៧-២០០៧/អជសង ប្រតិចារិត ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩, E1/3.1 នៅទំព័រ៩-១០ ។ មេធាវីការពារក្តីមិនឆ្លើយចំពោះសំណើនេះទេ ។ ប៉ុន្តែ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី Sarim Khan បានឆ្លើយតបៈ ពិតណាស់ យើងខ្ញុំឆ្លើយតបទៅនឹងសំណើដែលសហព្រះរាជអាជ្ញាគាត់បានលើកឡើងថា គាត់នឹងលើកឡើងទាក់ទងនឹងបញ្ហាសហឧក្រិដ្ឋកម្មរួម គឺខ្ញុំហាក់ដូចជាមិនច្បាស់លាស់ទាក់ទងនឹងវិធាននៃការអនុវត្តទៅបាន ហើយខ្ញុំធ្វើការឆ្លើយតបក្នុងនាមជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលយើងតំណាងទៅលើ គភាំទៅលើអង្គហេតុ ប៉ុន្តែគោលការណ៍មួយដែលយើងត្រូវចាំនោះ គឺថានៅពេលយើងធ្វើតុល្យភាពទាក់ទងនឹងការចូលរួមដែលថាយើងគួរបញ្ចូលនៅក្នុងសាលាក្តីនេះដែរឬទេ? គឺវាទាក់ទងនឹងបញ្ហាអង្គសេចក្តី គឺវាសំខាន់ណាស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលខ្ញុំតំណាង គឺថាសេចក្តីសម្រេចនោះគឺមិនត្រូវធ្វើឱ្យមានការពន្យារពេលទៅលើដំណើរនេះទេ ។ លោកចៅក្រមយល់អំពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងលិខិតុបករណ៍អន្តរជាតិនានាទៀត ហើយនិងសិទ្ធិនៃការការពារក្តីដែលថា ចុងចោទគាត់ទទួលបានការជូនដំណឹងផ្សេងៗ ។ ដូច្នេះ ខ្ញុំលើកឡើងអំពីបញ្ហានេះនៅទីនេះ ទាក់ទងនឹងសហមេធាវី ទាក់ទងទៅនឹងការចំពោះការដោះលែងឱ្យមានសេរីភាពដែលថាដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនោះគឺថា គឺខ្ញុំឱ្យលោកចៅក្រមយកទៅពិចារណាទៅលើបញ្ហាអង្គសេចក្តីវិញ ទៅលើករណីនេះ ។
ដូចខាងលើ នៅទំព័រ ១២ ។

[12] សូមកត់សម្គាល់ថាអង្គជំនុំជម្រះពិចារណាថា "សំណើរបស់ កសព ទាក់ទងនឹង JCE អាចត្រូវបានបង្ហាញទាន់ពេលវេលានិងក្នុងលក្ខណៈទូលំទូលាយ..." តែដោយសារ កសព បានលើកឡើងបញ្ហានេះតែនៅសវនាការបឋម ប៉ុន្តែ បានធ្វើសារណាពិតប្រាកដរបស់ខ្លួននៅពេលក្រោយ ។ *ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច* ០០១/១៨-០៧-២០០៧/អជសង សាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រម ឌុច) នៅកថាខណ្ឌទី៥០២ ។

[13] បញ្ជាក់បន្ថែម ។

00686145



ដែលនីតិវិធីនេះ ត្រូវបានកែប្រែដើម្បីតម្រូវថាបញ្ហានេះ ត្រូវតែបានលើកនៅក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីដីកាដំណោះស្រាយចូលជាស្ថាពរ ។

៩. កសព និយាយយោងទៅវិធាន៩៨ នៃវិធានផ្ទៃក្នុង ដើម្បីធ្វើជាមូលដ្ឋានគាំទ្រការលើកឡើងពីបញ្ហាទាំងនេះនៅសវនាការបឋម[14]។ វិធាន៩៨(២) ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា"សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះ អាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែ មិនអាចបញ្ចូលធាតុផ្សំថ្មីនៃបទចោទបានឡើយ[15]" វិធាននេះ និយាយយោងទៅរកសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង។ វិធាននេះមិនអនុញ្ញាតឱ្យ កសព លើកទឡ្ហីករណ៍ក្នុងសវនាការបឋមដែលខ្លួនមិនបានលើកឡើងក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ ដូចដែលបានតម្រូវដោយវិធាន៨៩ នៃវិធានផ្ទៃក្នុងឡើយ។

១០. បើទោះបីជា កសព ត្រូវបានអនុញ្ញាតឱ្យលើកពីបញ្ហាទាំងនេះក៏ដោយ អង្គជំនុំជម្រះសាលាដំបូងអាចមិនកែប្រែច្បាប់ដែលនៅជាធរមាន តាមការស្នើសុំរបស់ កសព ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

ទី១ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងអាចផ្លាស់ប្តូរការកំណត់បទចោទ តាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង តែក្នុងករណីដែលការផ្លាស់ប្តូរការកំណត់បទចោទនោះមិនរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទតែប៉ុណ្ណោះ[16]។ វាច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូង នឹងរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុវត្តឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវដែលមិនមានចែងក្នុងច្បាប់ជាធរមាននៅក្នុងពេលវេលាពាក់ព័ន្ធ។ ការផ្លាស់ប្តូរការកំណត់បទចោទដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយការដកចំណងពាក់ព័ន្ធលក្ខខណ្ឌតម្រូវជម្លោះប្រដាប់អាវុធចេញពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬក៏ដាក់បញ្ចូលការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងតម្រូវឱ្យមានការ

[14] ការបង្ហាញបញ្ហាច្បាប់របស់ កសព, ទំព័រទី៩។

[15] គូសបញ្ជាក់បន្ថែម។

[16] សាលក្រមលើរឿងក្តី ឌុច, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌទី៤៩១។

អនុវត្តនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមិនមានចែងក្នុងច្បាប់ជាធរមានពីឆ្នាំ ១៩៧៥ ដល់១៩៧៩[17]។ ការដាក់បញ្ចូល JCE ទម្រង់ III ទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមរយៈ "ការផ្លាស់ប្តូរការកំណត់បទចោទ" ក៏ត្រូវបានហាមឃាត់ផងដែរ ។ JCE ទម្រង់ III មិនមានចែងក្នុងច្បាប់ជាធរមានក្នុងអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩ ដូចដែលបានលើកឡើងនៅក្នុងសាលដីកាកម្រាស់ ៦៩ ទំព័រ របស់អង្គបុរេជំនុំជម្រះដែលក្នុងនោះអង្គបុរេជំនុំជម្រះបានធ្វើការវិភាគស៊ីជម្រៅលើសេចក្តីសម្រេច *Tadic* ដែល JCE ទម្រង់ III លេចចេញជារូបរាងឡើង ប៉ុន្តែ មិនត្រូវបានគេលើកយកមកអនុវត្តឡើយ[18]។

ទី២ វិធាន៩២ (២) មិនមានធាតុផ្សំថ្មីណាមួយ ត្រូវបានដាក់បញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ។ ការដកចំណងពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃជម្លោះប្រដាប់អាវុធ នឹងពង្រីកវិសាលភាពនៃឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងអាចប៉ះពាល់ដល់ជនជាប់ចោទ ។ ដូច្នេះ វាច្បាស់ជានឹងមានផលប៉ះពាល់ដូចនឹងការដាក់បញ្ចូលធាតុផ្សំថ្មីចំពោះបទល្មើសផងដែរ ដូច្នេះគេត្រូវតែពិចារណាពីបញ្ហានេះ។ ការផ្លាស់ប្តូរការកំណត់បទចោទក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីដាក់បញ្ចូលការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងតម្រូវឱ្យមានការដាក់បញ្ចូលធាតុផ្សំថ្មីដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ការផ្លាស់ប្តូរការកំណត់បទចោទក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីដាក់បញ្ចូល JCE ទម្រង់ III ក៏មិនត្រូវបានគេអនុញ្ញាតដែរ ព្រោះ JCE ទម្រង់III មានធាតុផ្សំខុសប្លែកពីធាតុផ្សំរបស់ JCE ទម្រង់ I និង JCE ទម្រង់ II[19] ។ម្យ៉ាងវិញទៀត ការផ្លាស់ប្តូរការកំណត់បទចោទទាំងនេះ នឹងតម្រូវឱ្យមានការកែប្រែច្បាប់ដែលអនុវត្តនៅ អវតក ។ វិធាន ៩៨(២) នៃ

---

[17] សូមមើលសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១, ឯកសារ D427/1/30, កថាខណ្ឌ៣៧១ ដល់៣៧២, ៣១១។

[18] សូមមើលសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើ សហឧក្រិដ្ឋកម្មរួម (JCE), ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០, ឯកសារ D97/14/15។

[19] មិនដូចជា JCE ប្រភេទI និង JCE ប្រភេទ II ឡើយ JCE ប្រភេទ III លើកឡើងពីការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គល ក្នុងស្ថានភាពដែល "ទាក់ទងនឹងគោលបំណងរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងករណីដែលជនដៃ ដល់ម្នាក់ក្នុងចំណោមជនដៃដល់ដទៃទៀតប្រព្រឹត្តឧក្រិដ្ឋកម្មដែលផលប៉ះពាល់នៃការប្រព្រឹត្តក្នុងគោលបណងរួមនោះអាចត្រូវ បានគេប្រមើលទុកជាមុនបាន ប៉ុន្តែការប្រព្រឹត្តនោះមិនស្ថិតក្នុងផែនការរួមឡើយ"។ សូមមើលរឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Vasiljević*, IT-98-32-A, សាលក្រម, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤, កថាខណ្ឌទី៩៩។

វិធានផ្ទៃក្នុង មិនត្រូវយកមកបកស្រាយដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលដំបូងកែប្រែច្បាប់ឡើយ ប៉ុន្តែដើម្បីឱ្យអង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទទាក់ទងនឹងអង្គហេតុតែប៉ុណ្ណោះ ។ នេះគឺជាវិធីដែលអង្គជំនុំជម្រះសាលាដំបូងបកស្រាយវិធាននេះក្នុង ករណី ០០១[20] ។ ក្នុងករណីដែលមានមន្ទិលសង្ស័យក្នុងការបកស្រាយវិធាន នោះការបកស្រាយត្រូវជាប្រយោជន៍ដល់ជនជាប់ចោទ[21]។

នៅចុងបញ្ចប់ វិធាន៩៨(២) មិនអនុញ្ញាតឱ្យផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវឡើយ។ ម្យ៉ាងវិញទៀតវិធាននេះចែងថាអង្គជំនុំជម្រះសាលាដំបូង "អាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ[22]"។ សហឧក្រិដ្ឋកម្មរួមមិនមែនជាបទឧក្រិដ្ឋឡើយ ប៉ុន្តែជាទម្រង់នៃការទទួលខុសត្រូវ ។ អង្គជំនុំជម្រះសាលាដំបូងក្នុងករណី ០០១ បានកំណត់ថា វិធាន៩៨(២) នៃវិធានផ្ទៃក្នុង មិនអនុញ្ញាតឱ្យផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវឡើយ ប៉ុន្តែបានធ្វើការកត់សម្គាល់ថា សមត្ថភាពរបស់ខ្លួនក្នុងការផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវ មិនដែលត្រូវបានភាគីតវ៉ាឡើយ[23] ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវបានអនុញ្ញាតដោយវិធាន៩៨(២) នៃវិធានផ្ទៃក្នុង ឱ្យផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវ ព្រោះវិធានផ្ទៃក្នុងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិអនុញ្ញាតឱ្យមាន "ការផ្លាស់ប្តូរការកំណត់បទចោទចំពោះបទល្មើសដើម្បីឱ្យស្របទៅនឹងទម្រង់នៃការចូលរួមប្រព្រឹត្ត[24]" ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "ទោះបីជាបទប្បញ្ញត្តិនានានៅក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មិនមានចែងយ៉ាងច្បាស់ទាក់ទងនឹង

---

20 " ផ្ទុយទៅវិញ មូលដ្ឋាននៃការផ្លាស់ប្តូរការកំណត់បទចោទនៅចំពោះមុខ អវតក គឺវិធាន៩៨ (២) ដែលបានចែងពីករណីនេះយ៉ាងច្បាស់ដោយឈរលើមូលដ្ឋាននៃការការពារការជំនុំជម្រះក្តីដោយយុត្តិធម៌"។ ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៤៩៥។ "<u>ស្រដៀងគ្នានេះដែរ</u> វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានអនុញ្ញាតឱ្យអង្គជំនុំជម្រះរបស់ខ្លួនផ្លាស់ប្តូរការកំណត់បទចោទបន្ទាប់ពីការចាប់ផ្តើមនីតិវិធីជំនុំជម្រះ "។ ដូចជើងទំព័រខាងលើ (គូសបញ្ជាក់បន្ថែម)។

21 ក្នុងករណីមានវិមតិសង្ស័យ អង្គជំនុំជម្រះសាលាដំបូងត្រូវតែគោរពគោលការណ៍ធម្មនុញ្ញនៃគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (*in dubio pro reo)* ស្របតាមវិធានមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ដែលត្រូវបានធ្វើវិសោធនកម្មកាលពីឆ្នាំ១៩៩៩។

22 គូសបញ្ជាក់បន្ថែម។

23 សូមមើលសាលក្រមលើករណី ឌុច, កថាខណ្ឌទី៤៩៣។

24 ដូចគ្នា, ជើងទំព័រ៨០៧។

ការផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ការផ្លាស់ប្តូរការកំណត់បទចោទនេះ ត្រូវបានអនុញ្ញាតផ្អែកតាមវិធាន៩៨(២)[25]”ដែរ ។ អង្គជំនុំជម្រះសាលាដំបូង *ត្រូវតែ*ពិចារណាការសន្និដ្ឋានពីករណី០០១ ព្រោះច្បាប់កម្ពុជាដែលនៅជាធរមាន *មិនអនុញ្ញាត*ឲ្យមានការផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវបែបនេះឡើយ[26] ហើយដោយសារតែខ្លឹមសារនៃវិធាន៩៨(២) ខុសគ្នាពីខ្លឹមសារនៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

១១. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងកំណត់ថា កសព អាចលើកបញ្ហាទាំងនេះនៅសវនាការបឋម ទោះបីជាមានទឡ្ហីករណ៍ប្រឆាំងនឹងការលើកឡើងពីបញ្ហានេះ នោះមេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យ កសព ផ្តល់សារណាជាលាយលក្ខណ៍អក្សរលម្អិតនៅមុនសវនាការបឋម ដោយគូសបញ្ជាក់ពីទឡ្ហីករណ៍របស់ខ្លួនទាក់ទងនឹងថាតើហេតុអ្វីបានជាសំណើសុំផ្លាស់ប្តូរការកំណត់បទចោទនេះ ត្រូវបានអនុញ្ញាត និងដើម្បីឲ្យមេធាវីការពារក្តីអាចដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសារណានេះ ។ សារណាបែបនេះចាំបាច់ត្រូវតែមាន ព្រោះបញ្ហាទាំងនេះ ជាបញ្ហាច្បាប់ដ៏ស្មុគស្មាញ ហើយភាគីនឹងជួយអង្គជំនុំជម្រះសាលាដំបូងឲ្យបានច្រើនបំផុត ដោយការរៀបចំសារណាជាលាយណ៍លក្ខអក្សរលម្អិត និងប្រកបដោយការប្រុងប្រយ័ត្ន ដែលក្រោយមកទៀតនឹងអាចត្រូវបានគេលើកមកអះអាងបញ្ជាក់ និងធ្វើការពន្យល់ដោយលម្អិតបន្ថែមទៀតជាសារណាផ្ទាល់មាត់ក្នុងសវនាការបឋម។

## III. **សំណើ**

**អាស្រ័យហេតុនេះ** ដោយមានហេតុផលទាំងអស់ដែលបានលើកឡើងនៅទីនេះ មេធាវីការពារក្តីសូមអញ្ជើញអង្គជំនុំជម្រះសាលាដំបូងពិចារណាលើការអង្កេតទាំងនេះ និង៖

ក. **បដិសេធ**ចោលការប៉ុនប៉ងរបស់ កសព ក្នុងការលើកបញ្ហាទាំងនេះនៅសវនាការបឋម ឬ

ខ. **បង្គាប់ឲ្យ** កសព ផ្តល់សារណាជាលាយលក្ខណ៍អក្សរលម្អិតដែលគូសបញ្ជាក់ពីទឡ្ហីករណ៍ទាក់ទងនឹងមូលហេតុអ្វីបានជាការផ្លាស់ប្តូរច្បាប់ជាធរមានដែលបានបញ្ជាក់ក្នុងដីកាបញ្ជូនរឿងទៅ

---

[25] ដូចជើងទំព័រខាងលើ, កថាខណ្ឌ៤៩៣។

[26] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា “ប្បញ្ញត្តិនានានៅក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជាមិនមានចែងយ៉ាងច្បាស់ទាក់ទងនឹងការផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវ...” ដូចជើងទំព័រខាងលើ។

00686149



ជំនុំជម្រះ ត្រូវតែបានអនុញ្ញាត្ត និងអនុញ្ញាតឲ្យមេធាវីការពារក្តីដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះសារណានេះ ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី